**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ៥១០ សសរ. កសក

# សេចក្តីសម្រេច
# ស្តីពី
# ការកែសម្រួលសមាសភាពគណៈកម្មការជំនាញអភិវឌ្ឍបទដ្ឋានគតិយុត្ត ក្រោមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/ ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/ ៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៥ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារ ភារកិច្ចឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញសេចក្តីសម្រេចលេខ២៧២ សសរ.កសក ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៦ ស្តីពីរបៀបរបបការងារនិងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

# ស ម្រេ ច

**ប្រការ ១.-**

ត្រូវបានកែសម្រួលសមាសភាពគណៈកម្មការជំនាញអភិវឌ្ឍបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ដែលមានដូចខាងក្រោមៈ

| | | |
|---|---|---|
| ១- ឯកឧត្តម **យុទ្ធ ភូថង** | រដ្ឋលេខាធិការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២- ឯកឧត្តម **ហ៊ីង ម៉ុនណារី** | អនុរដ្ឋលេខាធិការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៣- លោក **អ៊ុក ស៊ីផាន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកសិកម្ម | អនុប្រធាន |
| ៤- លោក **សៀ រ៉ា** | អនុប្រធានរដ្ឋបាលព្រៃឈើ | អនុប្រធាន |
| ៥- លោក **គុំ រ៉ា** | អនុប្រធានទទួលបន្ទុករួមនាយកដ្ឋាននីតិកម្មកសិកម្ម | សមាជិកអចិន្ត្រៃយ៍ |
| ៦- លោក **មួន សុវណ្ណា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកៅស៊ូ | សមាជិក |
| ៧- លោក **ម៉ឹក គឹមស្រួយ** | អនុប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម | សមាជិក |
| ៨- លោក **សួន សុធឿន** | អនុប្រធាននាយកដ្ឋានផលិតកម្មនិងបសុព្យាបាល | សមាជិក |
| ៩- លោក **ឡេង ស្រេង** | អនុប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម | សមាជិក |
| ១០- លោក **ទី ចាន់ថា** | អនុប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម | សមាជិក |
| ១១- លោក **ម៉ុច ចន្ថា** | អនុប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម | សមាជិក |
| ១២- លោក **សំ សត្យា** | អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលនិងនីតិកម្មនៃរដ្ឋបាលជលផល | សមាជិក |
| ១៣- លោក **ហេង ឈុនហ៊ី** | អនុប្រធាននាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យនៃអគ្គនាយកដ្ឋានកសិកម្ម | សមាជិក |
| ១៤- លោក **ម៉ែ សាធុន** | អនុប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ | សមាជិក |
| ១៥- លោក **អោះ ឈីណា** | អនុប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស | សមាជិក |
| ១៦- លោក **ម៉ិច ធុច** | អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល | សមាជិក |
| ១៧- លោក **សេង ម៉ាង** | នាយករងវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា | សមាជិក |
| ១៨- លោក **តាង ជិនថេង** | អនុប្រធានមន្ទីរពិសោធន៍ជាតិកសិកម្មនៃអគ្គនាយកដ្ឋានកសិកម្ម | សមាជិក |
| ១៩- លោក **ឡោ ម៉ាន់ណុល** | ប្រធានការិយាល័យវិភាគកសិកម្មនិងស្រាវជ្រាវនៃនាយកដ្ឋាននីតិកម្មកសិកម្ម | សមាជិក |
| ២០- លោក **ស៊ិន សាធុទ្ធ** | ប្រធានការិយាល័យនីតិកម្មកសិកម្មនិងផ្សព្វផ្សាយច្បាប់កសិកម្មនៃនាយកដ្ឋាននីតិកម្មកសិកម្ម | សមាជិក |
| ២១- លោក **មេ សៀកម៉េង** | អនុប្រធានការិយាល័យបមាណីយសម្ភារកសិកម្មនៃនាយកដ្ឋាននីតិកម្មកសិកម្ម | សមាជិក |
| ២២- លោក **លីម ចូលីន** | មន្ត្រីនាយកដ្ឋាននីតិកម្មកសិកម្ម | លេខាធិការ |
| ២៣- កញ្ញា **ទិនិន ម៉ារីណែត** | មន្ត្រីនាយកដ្ឋាននីតិកម្មកសិកម្ម | លេខាធិការ |
| ២៤- លោក **ថា សុភ័ក្ត្រ** | មន្ត្រីនាយកដ្ឋាននីតិកម្មកសិកម្ម | លេខាធិការ។ |

**ប្រការ ២.-**

គណៈកម្មការជំនាញនេះមានភារកិច្ចពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម នៅថ្នាក់ក្រសួង និងថ្នាក់អន្តរក្រសួងដែលពាក់ព័ន្ធ។

អនុប្រធាន និងសមាជិកនៃគណៈកម្មការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

ប្រធានអាចអញ្ជើញមន្ត្រីជំនាញមកពីអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង ឬក្រុមការងារបទដ្ឋានគតិយុត្តរបស់ក្រសួងដែលពាក់ព័ន្ធ ដើម្បីចូលរួមប្រជុំគណៈកម្មការជំនាញ ក្នុងករណីមានការចាំបាច់។

**ប្រការ ៣.-**

សេចក្តីសម្រេចលេខ៤៧៨ សសរ.កសក ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មការដឹកនាំអភិវឌ្ឍន៍បទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៤.-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធានអង្គភាពពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ២០១៦

**រ ដ្ឋ ម ន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ